# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីពាក្យថា ធម្មាធិបតេយ្យនិងប្រជាធិបតេយ្យ

Website: www.hoksavann.org

ថ្ងៃទី២១ វិច្ឆិកា ២០០៤

**១- អំពីពាក្យថា ធម្មាធិបតេយ្យ ៖**

ពាក្យថាធម្មាធិបតេយ្យ មកអំពីពាក្យថា ធម្មានិងអធិបតេយ្យ ប្រែថា មានធម៌ជាអធិបតី ឬមានធម៌ជាធំ ។ ពាក្យធម៌ក្នុងទីនេះ សំដៅយកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលនិយាយពីការពិតជាសច្ចធម៌ ដែលណែនាំមនុស្សនិងសង្គមមនុស្សទៅរកសេចក្តីសុខសន្តិភាព ។ ផ្លូវធម៌នេះជាច្បាប់សកល ជាច្បាប់យុត្តិធម៌ ដែលរកឃើញនិងសំដែងដោយព្រះសម្មាសម្ពុទ្ធជាង២៥០០ឆ្នាំមកហើយ ។ ព្រះពុទ្ធដីកាសំដែងយ៉ាងណាហើយនៅតែការពិតយ៉ាងនោះ គ្រប់ទីកន្លែងនិងគ្រប់កាលៈទេសៈ ដូចជាពាក្យថា កើតចាស់ឈឺស្លាប់ បុណ្យបាបគុណទោស មគ្គផលនិពាន្ធជាដើម ។ ផ្លូវធម៌គឺនិយាយពីការពិតជាតថភាព ការពិតយ៉ាងណានិយាយយ៉ាងនោះ ជាយថវត្ថុ គឺនិយាយពីការពិតទៅតាមពិត ពុំមែននិយាយតាមការចូលចិត្ត ឬតាមជំនឿនោះឡើយ ។ ការយកធម៌ជាធំមានន័យថា មុននឹងធ្វើការងារអ្វីមួយបានគិតពិចារណាថា អំពើដែលបំរុងនឹងធ្វើនោះ តើមានខុសផ្លូវធម៌ឬទេ ? បើឃើញថាអំពើនោះត្រឹមត្រូវតាមផ្លូវធម៌ហើយ ទើបសំរេចចិត្តធ្វើ ។ អំពើត្រឹមត្រូវជាផ្លូវធម៌ គឺប្រព្រឹត្តអំពើល្អជាកុសល ជៀសវាងអំពើអកុសល អំពើបៀតបៀន អំពើអយុត្តិធម៌ នេះហៅថាធម្មាធិបតេយ្យយកធម៌ជាធំ ។ ប្រៀបដូចអ្នកគោរពច្បាប់ផ្លូវអាណាចក្រ ពុំហ៊ានប្រព្រឹត្តធ្វើអំពើណាមួយដែលខុសច្បាប់រដ្ឋ ។ បើនិយាយអំពីសង្ឃកម្មរបស់ព្រះសង្ឃព្រះពុទ្ធសាសនា ដែលបានព្រមព្រៀងគ្នាបំពេញកិច្ចការអ្វីមួយរបស់ព្រះសង្ឃ ត្រូវសំរេចឡើងដោយមតិភាគច្រើនរបស់ព្រះសង្ឃ ហៅថាសំរេចប្រកបដោយធម៌ យកធម៌ជាធំ ហើយនោះក៏ចាត់ជាប្រជាធិបតេយ្យរបស់ព្រះពុទ្ធសាសនាដូចផ្លូវអាណាចក្រដែរ ។

**២- អំពីពាក្យថាប្រជាធិបតេយ្យ ៖**

ពាក្យថាប្រជាធិបតេយ្យប្រែថា មានប្រជាពលរដ្ឋជាធំ ជាអធិបតី គឺពោលដល់អំណាចរបស់រដ្ឋ ត្រូវកើតចេញមកពីប្រជាពលរដ្ឋ ។ នៅក្នុងប្រទេសដែលមានប្រជាធិបតេយ្យ គេបានចាត់ចែងឲ្យប្រជាពលរដ្ឋជ្រើសរើសតំណាងរបស់ខ្លួន ដែលហៅថាតំណាងរាស្ត្រ ជាអ្នកកាន់នីតិបញ្ញត្តិ តាមរយៈការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ជាអ្នកបញ្ញត្តិច្បាប់ ។ រួចហើយជ្រើសរើសរដ្ឋាភិបាលដឹកនាំប្រទេស ជាអ្នកកាន់នីតិប្រតិបត្តិ ។ អំណាចមួយទៀត គឺអំណាចតុលាការ ជាស្ថាប័នរកយុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់ឋានៈនៅក្នុងប្រទេស ។ អំណាចទាំងបី គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ នឹងអំណាចតុលាការ ត្រូវឲ្យដាច់ពីគ្នាដោយឯករាជ្យរៀងខ្លួន ។ បើអំណាចទាំងបីនេះនៅជាមួយគ្នា ការអនុវត្តន៍ពុំមានយុត្តិធម៌ឡើយ គឺជារបបផ្តាច់ការ ។ បានសេចក្តីថា ធ្វើច្បាប់ខ្លួនឯង អនុវត្តច្បាប់ខ្លួនឯង កិច្ចការគ្រប់យ៉ាងសំរេចថាមានយុត្តិធម៌ឬពុំមានយុត្តិធម៌ដោយខ្លួនឯង ឧទាហរណ៍ចោទមនុស្សដោយខ្លួនឯង សំរេចឲ្យមានទោសដោយខ្លួនឯង ធ្វើទោសមនុស្សដោយខ្លួនឯង បែបនេះពុំមានយុត្តិធម៌ឡើយ ។ បើនិយាយឲ្យងាយយល់ គឺប្រជាពលរដ្ឋទាំងអស់ ពុំអាចទៅកាន់ការខាងនីតិបញ្ញត្តិ ខាងរដ្ឋាភិបាល និងខាងតុលាការទាំងអស់គ្នាបានទេ គឺត្រូវតែជ្រើសរើសតំណាងរបស់ខ្លួន ឲ្យទៅធ្វើការជំនួសខ្លួន ដូចពោលមកហើយនេះឯង ។ ដើម្បីអនុវត្តលទ្ធិប្រជាធិបតេយ្យនេះឲ្យមានប្រសិទ្ធិភាព លុះត្រាតែប្រជាពលរដ្ឋមានសេរីភាពជាមូលដ្ឋានពេញបរិបូណ៌ ព្រោះលទ្ធិប្រជាធិបតេយ្យជាទ្រឹស្តីមួយចែងថា អំណាចរបស់រដ្ឋគ្រប់យ៉ាងត្រូវកើតចេញមកពីប្រជាពលរដ្ឋដែលជាម្ចាស់អំណាច ។

បើគេយកធម្មាធិបតេយ្យរបស់ព្រះពុទ្ធសាសនាមកប្រៀបធៀបនឹងប្រជាធិបតេយ្យរបស់ផ្លូវអាណាចក្រ នឹងមានលក្ខណៈដូចគ្នានិងខុសគ្នាដូចតទៅនេះ ៖

១- ដូចគ្នាត្រង់ការសំរេចកិច្ចការធំៗរបស់សង្គម ត្រូវយកតាមមតិភាគច្រើនរបស់សមាជិកដែលបានអនុម័ត ។

២- ខុសត្រង់លទ្ធិប្រជាធិបតេយ្យរបស់ផ្លូវអាណាចក្រ សំរេចតាមមតិភាគច្រើននៃសមាជិកសង្គម ប៉ុន្តែពុំបានគិតពីតម្លៃនៃការសំរេចនោះទេ ។ ប៉ុន្តែមានភាពល្អត្រង់អំណាចទាំងបីធ្វើការមានកំណត់ឆ្នាំ ដើម្បីឲ្យប្រជាពលរដ្ឋពិនិត្យមើលសកម្មភាពធ្វើការ តើចំរើនឬពុំចំរើន ហើយប្រជាពលរដ្ឋបញ្ចេញមតិសារជាថ្មី ។ ឯធម្មាធិបតេយ្យរបស់ព្រះពុទ្ធសាសនា បើពិនិត្យមើលកិច្ចការរបស់ព្រះសង្ឃដែលហៅថាសង្ឃកម្មដូចជាកឋិនកម្មជាដើម គឺព្រះសង្ឃដែលអាចក្រាលគ្រងកឋិនបាន លុះត្រាតែមានការស្រុះស្រួលយល់ព្រមពីព្រះសង្ឃដទៃទៀតក្នុងអង្គប្រជុំ ហើយព្រះសង្ឃដែលក្រាលគ្រងនោះ មានសមត្ថភាពនិងមានគុណភាព ដែលអាចក្រាលគ្រង ធ្វើឲ្យកឋិនសំរេចផងនិងញ៉ាំងព្រះសង្ឃឲ្យត្រេកអរផង ទើបឈ្មោះថាប្រកបដោយធម៌ ។ ដូច្នេះប្រជាធិបតេយ្យរបស់ព្រះពុទ្ធសាសនា មិនយកជាប្រមាណត្រឹមតែភាគច្រើនទេ ត្រូវមានលក្ខណៈមួយទៀត គឺសមត្ថភាពនិងគុណធម៌ ។៚